ខ្លឹមសារសង្ខេបនៃ
ឯកសារយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១១-២០១៨

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និង ចក្ខុវិស័យវែងឆ្ងាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា កម្ពុជាមិនត្រឹមតែអាចរំដោះខ្លួនចេញផុតពីសង្គ្រាម ហើយកសាងបាននូវសុខសន្តិភាពនៅទូទាំងបូរណភាពដែនដីប៉ុណ្ណោះទេ តែថែមទាំងអាចកសាង និងអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងសន្ទុះលឿន និងឆាប់រហ័សក្នុងរយៈកាល ២ ទសវត្សរ៍ចុងក្រោយនេះថែមទៀតផង ជាពិសេស គឺការសម្រេចបាននូវការអភិវឌ្ឍសង្គម ការផ្តល់សេចក្តីសុខក្សេមក្សាន្ត និងវិបុលភាពជូនប្រជាជនកម្ពុជា ។ ជាក់ស្តែង ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ កម្ពុជារក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាង ១% ក្នុងមួយឆ្នាំ ។ ជាពិសេសជាងនេះទៅទៀត ក្នុងឆ្នាំ ២០០៤-២០០៧ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី កម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចជាង ១០% ក្នុងមួយឆ្នាំ ហើយបើទោះបីជាមានវិបត្តិកលិយុគហិរញ្ញវត្ថុសាកលលោកឆ្នាំ ២០០៨-២០០៩ ក៏កម្ពុជានៅតែសម្រេចបានជាសារវន្តនូវកំណើនសេដ្ឋកិច្ចវិជ្ជមាន ០,១% ក្នុងឆ្នាំ ២០០៩ ខណៈពេលដែលប្រទេសជាច្រើនផ្សេងទៀត សម្រេចបានកំណើនអវិជ្ជមាន ។ នៅឆ្នាំ ២០១០ បើទោះបីស្ថិតក្នុងបរិការណ៍សេដ្ឋកិច្ចពិភពលោកមិនអនុគ្រោះម្តងទៀតក្តី ក៏កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ច ៦% ដែលស្ថានភាពនេះបង្ហាញថាសេដ្ឋកិច្ចកម្ពុជាបានឆ្លងកាត់ការលំបាកបំផុត រួចក៏បានស្ទុះងើបឡើងវិញតាមទម្រង់អក្សរ “V” ដែលកាលពីឆ្នាំ ២០០៨ សេដ្ឋកិច្ចមានកំណើន ៦,៨% ។ នៅឆ្នាំ ២០១០ កម្ពុជានៅតែអាចរក្សាកម្រិតអតិផរណាឱ្យនៅទាបក្នុងរង្វង់ ៤% ។ តាមការវាយតម្លៃ នៅឆ្នាំ ២០១១ សេដ្ឋកិច្ចកម្ពុជាអាចមានកំណើនជិត ៧% ទោះជាកម្ពុជាបានជួបប្រឈមនឹងកត្តាមិនអំណោយផលធំៗមួយចំនួន រួមទាំងគ្រោះទឹកជំនន់ដ៏ធ្ងន់ធ្ងរក៏ដោយ ។

ជោគជ័យនៃការសម្រេចបានសមិទ្ធិផលធំៗទាំងនេះ គឺមិនអាចកាត់ផ្តាច់ចេញពីការគ្រប់គ្រងបំណុលសាធារណៈដ៏មធ្យ័ត ប្រកបដោយចីរភាពរបស់រាជរដ្ឋាភិបាលបានឡើយ ។ ជាក់ស្តែង អនុបាតបំណុលសំខាន់ៗទាំងបីនាដើមទសវត្សរ៍ ឆ្នាំ ១៩៩០ គឺអនុបាតបំណុលធៀបនឹង ផសស មានប្រមាណ ៧៣% អនុបាតបំណុលធៀបនឹងការនាំចេញ ប្រមាណ ៦៤៣% និង អនុបាតបំណុលធៀបនឹងចំណូលថវិកាជាតិ មានប្រមាណ ១ ៧៦៦% ។ បច្ចុប្បន្ន ចំពោះអនុបាតបំណុលធៀបនឹង ផសស បានធ្លាក់មកនៅក្នុងរង្វង់ត្រឹម ២៨% អនុបាតបំណុលធៀបនឹងការនាំចេញបានធ្លាក់មកនៅក្នុងរង្វង់ត្រឹម ៨៥% និង អនុបាតបំណុលធៀបនឹងចំណូលថវិកាជាតិបានថយចុះមកនៅត្រឹមរង្វង់ ២២១% ។ ជោគជ័យនេះ បានកើតចេញពីការគោរពវិន័យដ៏មុឺងម៉ាត់បំផុតក្នុងការគ្រប់គ្រងបំណុលសាធារណៈ ដោយអនុលោមតាមបញ្ញត្តិពាក់ព័ន្ធនានាជាធរមាន ជាពិសេសគឺការប្រកាន់គោរពអនុវត្តយ៉ាងខ្ជាប់ខ្ជួនឥតមានរវាត តាមគតិបណ្ឌិតគន្លឹះទាំង ៤ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលរួមមាន:

(១) ត្រូវខ្ចីក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ច អាចទ្រាំទ្របាន

(២) ត្រូវខ្ចីតែឥណទានដែលមានកម្រិតសម្បទានខ្ពស់

(៣) ត្រូវខ្ចីសម្រាប់តែវិស័យអាទិភាពសំដៅទ្រទ្រង់ចីរភាពកំណើន និងបង្កើនផលិតភាពសេដ្ឋកិច្ច និង

(៤) ត្រូវប្រើប្រាស់ឥណទានទាំងនោះ ប្រកបដោយតម្លាភាព និងមានប្រសិទ្ធភាពខ្ពស់បំផុត ។

បច្ចុប្បន្ន កម្ពុជាបានឈានដល់ដំណាក់កាលថ្មីមួយទៀតនៃកិច្ចអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួន គឺការបង្កើនទុនយ៉ាងគំហុក សម្រាប់បម្រើឱ្យការវិនិយោគលើវិស័យអាទិភាពគន្លឹះនានារបស់រាជរដ្ឋាភិបាល ជាពិសេសវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលមានផលិតភាពសេដ្ឋកិច្ចខ្ពស់ និងទ្រទ្រង់ចីរភាពកំណើន ។ រាជរដ្ឋាភិបាលបានមើលឃើញនូវប្រភពហិរញ្ញប្បទានសក្តានុពលធំៗពីរ សម្រាប់ហិរញ្ញប្បទានមុខចំណាយខាងលើ ហើយដែលត្រូវបានដាក់ឱ្យស្ថិតក្រោមវិសាលភាពនៃយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ គឺ (១) ការខ្ចី ដែលរួមមានការខ្ចីពីដៃគូអភិវឌ្ឍន៍ និងការបោះផ្សាយមូលបត្ររដ្ឋ និង/ឬ សញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ និង (២) ការវិនិយោគសាធារណៈពីវិស័យឯកជនលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលតម្រូវឱ្យមានការធានាពីរាជរដ្ឋាភិបាល ដូចជាការសាងសង់វារីអគ្គិសនី ការសាងសង់រោងចក្រផលិតថាមពលអគ្គិសនីដើរដោយធ្យូងថ្ម ការសាងសង់ខ្សែបញ្ជូនអគ្គិសនី និងគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងទៀត ។

យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈនេះ មិនមានវិសាលភាពគ្របដណ្តប់លើការគ្រប់គ្រងបំណុលរបស់វិស័យឯកជននៅកម្ពុជាទេ ។

យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ មានគោលដៅកៀរគរទុនហិរញ្ញវត្ថុសម្រាប់បំពេញតម្រូវការហិរញ្ញប្បទានចំទិសដៅចំណាយអាទិភាពរបស់រាជរដ្ឋាភិបាល ដោយកម្រិតបន្ទុកសេវាបំណុលរយៈពេលវែង និងហានិភ័យបំណុលទាំងក្នុងរយៈពេលខ្លី មធ្យម និងវែង ឱ្យស្ថិតក្នុងកម្រិតអប្បបរមា និងប្រុងប្រយ័ត្នខ្ពស់បំផុត ដើម្បីធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ការទ្រទ្រង់ចីរភាពកំណើននិងការអភិវឌ្ឍសេដ្ឋកិច្ច ។

យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធាណៈនេះ គឺជាក្របខ័ណ្ឌយុទ្ធសាស្ត្ររួម ដែលកំណត់គោលដៅ និងគោលការណ៍របស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រងបំណុលសាធារណៈរយៈពេល ០៨ឆ្នាំ (២០១១-២០១៨) អនុលោមតាមបរិការណ៍នៃក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ គោលនយោបាយថវិកា គោលនយោបាយរូបិយវត្ថុ ស្ថានភាពបំណុលបច្ចុប្បន្ន និងផែនការតម្រូវការហិរញ្ញប្បទាន ដោយត្រូវរក្សាហានិភ័យ និងបន្ទុកសេវាបំណុលឱ្យនៅកម្រិតអប្បបរមា ។

គិតត្រឹមដំណាច់ឆ្នាំ ២០១០ ដោយមិនគិតបញ្ចូលបំណុលចាស់ (បំណុលកំពុងដោះស្រាយ) កម្ពុជាមានសន្និធិបំណុលសរុបប្រមាណ ២ ៩៣០លានដុល្លារអាមេរិក ស្មើនឹង ២២,៣%នៃ ផសស ។ បើគិតទាំងបំណុលចាស់ សន្និធិបំណុលកម្ពុជាសរុប មានចំនួនជិត ៣ ៣០០ លានដុល្លារអាមេរិក ស្មើនឹង ២៩% នៃ ផសស ដោយភាគច្រើនលើសលុប (ជាង ៩៩% នៃបំណុលសរុប) ជាបំណុលសាធារណៈក្រៅប្រទេស ។ ឥណទានសម្បទានទាំងនេះភាគច្រើនជាឥណទានដែលមានកម្រិតសម្បទានខ្ពស់ ដោយមានអត្រាការប្រាក់ពី សូន្យ ទៅ ២% ក្នុងមួយឆ្នាំ រយៈពេលសងពី ២០ ទៅ ៤០ឆ្នាំ និងមានរយៈពេលអនុគ្រោះពី ៧ ទៅ ១៥ឆ្នាំ ។

តាមការព្យាករណ៍ដោយផ្អែកលើសន្និធិបំណុលសាធារណៈក្រៅប្រទេសនៅចុងឆ្នាំ ២០១០ បង្ហាញថា ក្នុងចន្លោះឆ្នាំ ២០១១-២០១៣ បន្ទុកសេវាបំណុលសាធារណៈក្រៅប្រទេសមានការកើនឡើងជាមធ្យមក្នុងរង្វង់

១៧% ក្នុងមួយឆ្នាំ ។ ជាក់ស្តែង នៅឆ្នាំ ២០១១ បន្ទុកនេះមានចំនួន ៧២,៣លានដុល្លារអាមេរិក ឆ្នាំ ២០១២ មានចំនួន ៨៨,៧លានដុល្លារអាមេរិក និងឆ្នាំ ២០១៣ មានចំនួន ១០៩,៨លានដុល្លារអាមេរិក ។ បន្ទុកសេវាបំណុលនេះ នឹងកើនឡើងដល់ប្រមាណ ១៥០ លានដុល្លារអាមេរិក នៅក្នុងឆ្នាំ ២០១៤-២០១៦ ហើយបន្តកើនឡើងថែមទៀតរហូតដល់ជាង ២០៨ លានដុល្លារអាមេរិក នៅឆ្នាំ ២០១៧ និងប្រមាណក្នុងរង្វង់ ២៥០ លានដុល្លារអាមេរិក នៅឆ្នាំ ២០១៨-២០២១ ។ ដូចនេះ ដើម្បីមានលទ្ធភាពអាចសងបន្ទុកសេវាបំណុល ទាំងក្នុងករណីដែលមិនមានការខ្ចីបន្ថែម និងទាំងក្នុងករណីដែលមានការខ្ចីបន្ថែម និង ដើម្បីអាចរក្សាបាននូវទំហំហិរញ្ញប្បទានលើគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលមានផលិតភាពសេដ្ឋកិច្ចខ្ពស់ និងទ្រទ្រង់ចីរភាពកំណើន រាជរដ្ឋាភិបាលត្រូវបន្តកិច្ចខិតខំប្រឹងប្រែងបង្កើនចំណូលថវិកាជាតិ តាមរយៈបន្តការពង្រីកមូលដ្ឋានប្រមូលចំណូលគ្រប់ប្រភេទ និងបន្តពង្រឹងប្រព័ន្ធពាក់ព័ន្ធនឹងកិច្ចការប្រមូលចំណូល ជាពិសេស ការអនុវត្តវិធានការតឹងទារបំណុល ពីក្រុមហ៊ុនដែលនៅជំពាក់ពន្ធរដ្ឋ ។

បន្ទុកសេវាបំណុលនឹងមានទំហំធំជាងចំនួនខាងលើនេះ ប្រសិនបើរាជរដ្ឋាភិបាលត្រូវរៀបចំកម្មវិធីសងបំណុលជាមរតកដែលកំពុងដោះស្រាយ ឬ/និង ត្រូវខ្ចីឥណទានថ្មីបន្ថែមសម្រាប់វិនិយោគលើវិស័យអាទិភាពរបស់រាជរដ្ឋាភិបាល ឬ/និង ត្រូវសងកាតព្វកិច្ចបំណុលជាយថាហេតុ ដូចជាបន្ទុកសេវាបំណុលដែលអាចកើតចេញពីការធានារបស់រដ្ឋលើគម្រោងវារីអគ្គិសនី គម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនី គម្រោងសាងសង់រោងចក្រផលិតអគ្គិសនីដើរដោយធ្យូងថ្ម និងគម្រោងផលិតថាមពលអគ្គិសនីឯករាជ្យ (Independent Power Producer – IPP) ព្រមទាំងគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន (Public Private Partnership – PPP) ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងទៀត ។

រាជរដ្ឋាភិបាលបានប្រមើលឃើញថា នាពេលអនាគត កាតព្វកិច្ចបំណុលជាយថាហេតុអាចនឹងកើតចេញពីការធានារបស់រដ្ឋលើគម្រោងក្នុងវិស័យអគ្គិសនី ដែលគិតត្រឹមឆ្នាំ ២០១១ រាជរដ្ឋាភិបាលបានផ្តល់ការធានាលើគម្រោងវារីអគ្គិសនី គម្រោងខ្សែបញ្ជូនអគ្គិសនី តាមរូបភាពសាងសង់ អាជីវកម្ម និង ផ្ទេរ (Build Operate Transfer – BOT) ចំនួន ០៨គម្រោង លើគម្រោងសាងសង់រោងចក្រផលិតអគ្គិសនីដើរដោយធ្យូងថ្ម តាមរូបភាពសាងសង់ ធ្វើម្ចាស់ និង អាជីវកម្ម (Build Own Operate – BOO) ចំនួន ០២គម្រោង និងលើគម្រោងទិញអគ្គិសនី ចំនួន ០១គម្រោង ។ កិច្ចព្រមព្រៀងទាំង ១១ នេះ មានទឹកប្រាក់សរុបប្រមាណជាង ២ ៥០០ លានដុល្លារអាមេរិក ដោយក្នុងនោះ រាជរដ្ឋាភិបាលធានាលើពីរករណីគឺ: (១) ករណីដែលអគ្គិសនីកម្ពុជាមិនមានលទ្ធភាពសង ដោយសារការធ្លាក់ចុះដុនដាបនៃស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន និង (២) ករណីមានប្រធានសក្តិនយោបាយ ដែលគម្រោងមិនអាចដំណើរការផលិត និងបញ្ជូនថាមពលអគ្គិសនីបាន តែករណីនេះសឹងតែមិនអាចកើតមានឡើងទេ ។

ចាប់ពីឆ្នាំ ២០១១ទៅ កម្ពុជាត្រូវប្រឈមនឹងនិន្នាកាថ្មីមួយ គឺសមាសភាគហិរញ្ញប្បទានសហប្រតិបត្តិការរបស់កម្ពុជានឹងមានការផ្លាស់ប្តូរ ដោយដៃគូអភិវឌ្ឍន៍បានងាកពីការផ្តល់ហិរញ្ញប្បទានតាមអភិក្រម ៥០% ជាហិរញ្ញប្បទានឥតសំណង និង ៥០% ជាឥណទានសម្បទាន មកជាការផ្តល់ឥណទានសម្បទាន ១០០% វិញ ។ ទន្ទឹមនឹងនេះ កម្រិតសម្បទាននៃឥណទានថ្មី ក៏នឹងប៉ះពាល់ដល់ស្ថានភាពបំណុលសាធារណៈរបស់កម្ពុជាផងដែរ

បើសិនជាកម្រិតសម្បទាននោះកាន់តែទាបទៅ ។ បន្ថែមពីលើនេះ រាជរដ្ឋាភិបាលក៏ត្រូវប្រឈមនឹងការដោះស្រាយបញ្ហាមរតកបំណុល ឱ្យជ្រះស្រឡះជាមួយដៃគូផ្សេងទៀតផងដែរ ។

ផ្អែកតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣ និង កម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០១២-២០១៤ កម្ពុជាមានកំណើនតម្រូវការហិរញ្ញប្បទានវិនិយោគមូលធនសាធារណៈជាមធ្យមប្រមាណ ១០% ក្នុងមួយឆ្នាំ ។ តាមការព្យាករណ៍ សម្រាប់ឆ្នាំ ២០១១-២០១៨ កម្ពុជាមានតម្រូវការហិរញ្ញប្បទានវិនិយោគមូលធនសាធារណៈសរុបប្រមាណជិត ១២ ០០០លានដុល្លារអាមេរិក ដោយក្នុងនោះ ហិរញ្ញប្បទានដោយធនធានក្នុងស្រុកមានចំនួនជាង ៣ ១០០លានដុល្លារអាមេរិក និងហិរញ្ញប្បទានដោយធនធានក្រៅប្រទេសមានចំនួនជិត ៨ ៧០០លានដុល្លារអាមេរិក ។ ដោយសារផលប៉ះពាល់នៃទឹកជំនន់ឆ្នាំ ២០១១ កម្ពុជានឹងមានតម្រូវការទុនវិនិយោគសាធារណៈច្រើន នៅឆ្នាំ ២០១២ ។

ផ្អែកតាមស្ថានភាពបំណុលបច្ចុប្បន្ន ផែនការតម្រូវការហិរញ្ញប្បទាន ព្រមទាំងអនុលោមតាមបរិការណ៍នៃក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ គោលនយោបាយថវិកា និង គោលនយោបាយរូបិយវត្ថុ រាជរដ្ឋាភិបាលបានកំណត់ទំហំនៃការខ្ចីឥណទានសម្បទានសម្រាប់ឆ្នាំ ២០១១-២០១៨ ក្នុងរង្វង់ ៤០០ លានអេសដេអ៊ែក្នុងមួយឆ្នាំ ហើយអាចមានលទ្ធភាពបង្កើនដល់ ៧០០ លានអេសដេអ៊ែក្នុងមួយឆ្នាំ ទៅតាមបរិការណ៍នៃគោលនយោបាយថវិកា និងវិវឌ្ឍនាការម៉ាក្រូសេដ្ឋកិច្ចជាក់ស្តែង ព្រមទាំងសម្រេចដាក់ចេញនូវវិធានការម៉ឹងម៉ាត់ក្នុងការគ្រប់គ្រងបំណុលសាធារណៈ ដូចខាងក្រោមៈ

១- បន្តប្រើប្រាស់ឥណទានសម្បទាន សម្រាប់វិនិយោគមូលធនលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលមានផលិតភាពសេដ្ឋកិច្ចខ្ពស់ និងទ្រទ្រង់ចីរភាពកំណើន រួមមាន ផ្លូវ ស្ពាន ទំនប់ ប្រឡាយ ប្រព័ន្ធស្រោចស្រព អគ្គិសនី កំពង់ផែ ការផ្គត់ផ្គង់ទឹកស្អាតនៅទីប្រជុំជន ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងទៀត សំដៅជំរុញការពង្រីកមូលដ្ឋានសេដ្ឋកិច្ច និងទ្រទ្រង់ចីរភាពកំណើនក្នុងរយៈពេលវែង ។

២- បន្តពង្រឹងបន្ថែមយន្តការគ្រប់គ្រង និងអនុវត្តគម្រោងវិនិយោគសាធារណៈឱ្យមានប្រសិទ្ធភាព ដោយត្រូវបន្តដាក់ចេញនូវរាល់បណ្តាលិខិតបទដ្ឋានគតិយុត្តិ គោលការណ៍ និងនីតិវិធីពាក់ព័ន្ធចាំបាច់នានា ជាពិសេស ការបន្តពង្រឹងអនុវត្តនីតិវិធីដែលកំពុងអនុវត្តជាធរមាន ដែលមានដូចជា នីតិវិធីរួមសម្រាប់ការគ្រប់គ្រងរដ្ឋបាល នីតិធីរួមសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ និងនីតិវិធីរួមសម្រាប់ការគ្រប់គ្រងលទ្ធកម្មគម្រោងហិរញ្ញប្បទានពីក្រៅប្រទេស សំដៅធានាបង្កើនប្រសិទ្ធភាពនៃចំណាយថវិកាគម្រោង តាមរយៈកិច្ចលទ្ធកម្មប្រកបដោយតម្លាភាព និងប្រសិទ្ធភាពខ្ពស់ ។

៣- បន្តរក្សាកម្រិតសម្បទាននៃឥណទានឱ្យបានខ្ពស់ ពោលគឺត្រូវទទួលយកតែឥណទានណាដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់ ដែលរួមមានកម្រិតអត្រាការប្រាក់ទាប រក្សារយៈពេលសង និងរយៈពេលអនុគ្រោះវែង អនុលោមទៅតាមលក្ខខណ្ឌវិនិច្ឆ័យនៃការអនុវត្តជាអន្តរជាតិ និងស្របទៅនឹងបរិការណ៍សេដ្ឋកិច្ចកម្ពុជា ឆ្នាំ ២០១១-២០១៨ ។

៤- បន្តជំរុញអនុវត្តគោលនយោបាយ និងកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាលក្នុងវិស័យសំខាន់ៗ សំដៅរក្សាចីរភាពកំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែង ក្នុងរង្វង់ ៦%-៧% ក្នុងមួយឆ្នាំ និង សម្រេចឱ្យបាន

ចំណូលថវិកាជាតិក្នុងរង្វង់ពី ១៣,៥% ទៅ ១៥% នៃ ផសស ដើម្បីឈានទៅសម្រេចគោលដៅនៃការកាត់បន្ថយភាពក្រីក្រឱ្យបានយ៉ាងតិចជាង ១% ក្នុងមួយឆ្នាំ ។ ក្នុងន័យនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបន្តខិតខំអនុវត្តគោលនយោបាយ និងគោលការណ៍ណែនាំនានារបស់រាជរដ្ឋាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការប្រមូលចំណូលគ្រប់ប្រភេទ ដើម្បីជាគុណប្រយោជន៍នៃថវិកាជាតិ សំដៅធានាស្ថិរភាពនៃការគ្រប់គ្រងថវិកា និងម៉ាក្រូសេដ្ឋកិច្ច ។

៥- បន្តអនុវត្តគោលការណ៍មជ្ឈការនៃការគ្រប់គ្រងបំណុលសាធារណៈ ដែលតាមនេះ មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមួយគត់ ក្រោមការប្រទានសិទ្ធិពីនាយករដ្ឋមន្ត្រី ដែលមានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ ការបោះផ្សាយមូលបត្ររដ្ឋ ការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ ការវិនិយោគលើអចលកម្មហិរញ្ញវត្ថុ ការធានា ការសន្យាផ្នែកហិរញ្ញវត្ថុនានា ការឱ្យប្រាក់គេខ្ចីទាំងក្នុងនិងក្រៅប្រទេស និងការរៀបចំរចនាសម្ព័ន្ធបំណុលសាធារណៈឡើងវិញ ។ គ្មានរដ្ឋមន្ត្រីដទៃណាទៀត ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល ប្រធានសហគ្រាសសាធារណៈ អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ឬមន្ត្រីសាធារណៈណាមួយ មានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ ឬ ឱ្យប្រាក់គេខ្ចី ឬ ចេញលិខិតធានា ឬ ក៏ធ្វើទង្វើណាផ្សេងៗទៀត ដោយផ្ទាល់ ឬ ដោយប្រយោល ដែលអាចនាំឱ្យកើតមាននូវបំណុល ឬ បន្ទុកហិរញ្ញវត្ថុផ្សេងទៀត ដោយផ្ទាល់ ឬ ដោយប្រយោលដល់ព្រះរាជាណាចក្រកម្ពុជាបានទេ ។

៦- បន្តពង្រឹងការកៀរគរហិរញ្ញប្បទានឥតសំណង និងពីប្រភពហិរញ្ញប្បទានផ្សេងទៀត សម្រាប់បម្រើឱ្យតម្រូវការវិនិយោគសាធារណៈ ។

៧- ពង្រឹងការតាមដានត្រួតពិនិត្យលើហានិភ័យបំណុលពាក់ព័ន្ធ ជាពិសេស ហានិភ័យនៃសន្ទនីយភាពក្នុងការទូទាត់សេវាបំណុល (Liquidity Risk) និងកាតព្វកិច្ចបំណុលជាយថាហេតុ ដែលកើតចេញពីការធានារបស់រដ្ឋ និងគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលមានផលិតភាពសេដ្ឋកិច្ចខ្ពស់ និងទ្រទ្រង់ចីរភាពកំណើន ក្នុងរយៈពេលវែង ។

៨- ពង្រឹងការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្សដែលចូលរួមបំពេញកិច្ចការគ្រប់គ្រងបំណុលសាធារណៈ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

រាជរដ្ឋាភិបាលនឹងបន្តតាមដានយ៉ាងយកចិត្តទុកដាក់ លើដំណើរការនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១១-២០១៨ នេះ ដើម្បីធានាបាននូវប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការគ្រប់គ្រងបំណុលសាធារណៈមួយប្រកបដោយចីរភាព ដែលជាផ្នែកមួយដ៏សំខាន់ក្នុងការចូលរួមលើកស្ទួយចីរភាពកំណើនសេដ្ឋកិច្ច ក្នុងរយៈពេលវែង និងការទ្រទ្រង់វិស័យសង្គមកិច្ច ដើម្បីសមធម៌ និង យុត្តិធម៌សង្គម ។